# សហគមន៍អ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់កម្ពុជា
## នៅភូមិស្រែប្រិយ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

*ដោយ ម៉ិល វាសនា, ធន ឆាយពិសិដ្ឋ, ប្រែង ពិសិដ្ឋ*

## សេចក្តីផ្តើម

*« សហគមន៍អ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់កម្ពុជា » ជាសហគមន៍ជនជាតិចាមមួយដែលមានមូលដ្ឋានកណ្តាលនៅវិហារកែវសអូរឫស្សី នៅភូមិស្រែប្រិយ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ទោះបីជាប្រើពាក្យ « សហគមហ៍ » ក្តី តែយើងអាចនិយាយបានថា ក្រុមកនអ៊ីម៉ាំសាន់ ជានិកាយមួយនៃនិកាយសាហ្វាអ៊ីរបស់សាសនាអ៊ិស្លាម ដែលកំពុងមានការគោរពប្រតិបត្តិនៅកម្ពុជា។ និកាយឬក្រុមកនអ៊ីម៉ាំសាន់មានរបៀបនៃការប្រតិបត្តិសាសនាអ៊ិស្លាមដោយឡែករបស់ខ្លួន ហើយមានតែនៅកម្ពុជាប៉ុណ្ណោះ។*

*អត្ថបទនេះនឹងសិក្សាអំពីប្រវត្តិនៃក្រុមកនអ៊ីម៉ាំសាន់ រចនាបថវិហារនិងសាឡាវ ស្ថានភាពភាសានិងអក្សរចាម ការប្រតិបត្តិវប្បធម៌ប្រពៃណីនិងទំនៀមទម្លាប់ និងភាពដោយឡែកនៃការគោរពប្រតិបត្តិសាសនាអ៊ិស្លាមនៃនិកាយក្រុមកនអ៊ីម៉ាំសាន់។*

## ប្រវត្តិក្រុមកនអ៊ីម៉ាំសាន់

*អ៊ីម៉ាំសាន់ មកពីពាក្យ អ៊ីម៉ាំ ដែលជាងាររបស់អាចារ្យដឹកនាំការសូត្រធម៌ ថ្វាយបង្គំ និងទេសនាក្នុងព្រះវិហារនៃសាសនាអ៊ិស្លាម និង សាន់ ជាឈ្មោះរបស់បុគ្គលមួយរូប។ ក្រុមកនអ៊ីម៉ាំសាន់ សំដៅដល់ក្រុមជនជាតិចាម ស្ថិតនៅក្នុងនិកាយសាហ្វាអ៊ី ដែលគោរពប្រតិបត្តិមេដឹកនាំសាសនាអ៊ិស្លាមមួយរូបឈ្មោះ សាន់ ជាបុគ្គលបរិសុទ្ធ ជាបុគ្គលដ៏ប្រសើរថ្លៃថ្លា និងជាព្រះ។*

*និកាយឬក្រុមកនអ៊ីម៉ាំសាន់គឺមានតែនៅកម្ពុជាប៉ុណ្ណោះ ដោយក្រុមឬនិកាយនេះមានប្រវត្តិកកើតឡើងនៅកម្ពុជាក្នុងសម័យឧត្តុង្គ ក្រោយជនជាតិចាមបានធ្វើអន្តោប្រវេសន៍មករស់នៅកម្ពុជា។ ព្រះបាទអង្គឌួងបានប្រទានគោរមងាររមេដឹកនាំសាសនាអ៊ិស្លាមនេះថា ឧកញ៉ាឃ្លួរ ជាមន្ត្រីកិត្តិយសរបស់ព្រះបរមរាជវាំង មានស័ក្តិប្រាំពីរហ៊ូពាន់(ស្មើនឹងស័ក្តិមន្ត្រីត្រួតពលចំនួន ៧ ពាន់នាក់)។ រហូតមកដល់ឆ្នាំ២០១៧ ក្រុមកនអ៊ីម៉ាំសាន់មានឧកញ៉ាឃ្លួរប្រាំបួនរូប(ប្រាំបួនជំនាន់)។*

*មានការចងចាំនិងដំណាលតៗគ្នាអំពីកំណាកំណើតនៃក្រុមកនអ៊ីម៉ាំសាន់ថា នៅសម័យឧត្តុង្គ លោកអាចារ្យ សាន់ ជាអាចារ្យដឹកនាំការសូត្រធម៌ ថ្វាយបង្គំ និងទេសនានៃសាសនាអ៊ិស្លាម*

ដ៏មានកិត្តិសព្ទនិងមានឥទ្ធិពលលើជនជាតិចាមប្រតិបត្តិសាសនាអ៊ិស្លាមនៅកម្ពុជា។ លោកបានជ្រើសរើសយកទីតាំងនៅទិសអាគ្នេយ៍នៃភ្នំព្រះរាជទ្រព្យ(អដ្ឋរស្ស)ជាកន្លែងសំណាក់ធម៌ ដោយបានជីកលុងដីធ្វើជារូងសម្រាប់តាំងសមាធិ។ ក្រោយពេល *អ៊ីម៉ាំសាន់* ទទួលមរណភាព អ្នកគោរពនិងដើរតាមឱវាទរបស់លោកបាននាំគ្នាចាកចេញពីតំបន់នោះ ទៅរស់នៅក្នុងតំបន់មួយចំនួនតាមបណ្តាខេត្តផ្សេងៗ ដូចជា ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកណ្តាលជាដើម។ ដោយយល់ថា *អ៊ីម៉ាំសាន់* ជាបុគ្គលបរិសុទ្ធ ជាបុគ្គលដ៏ប្រសើរថ្លៃថ្លា ក្រុមជនជាតិចាមដែលបានគោរពឱវាទរបស់លោក បានចាត់ទុកលោកជាព្រះមួយរបស់ពួកគេ[1] ។ បច្ចុប្បន្ន នៅលើភ្នំអដ្ឋរស្ស មានព្រះវិហារមួយមានឈ្មោះថា « ព្រះវិហារតាសាន់ » ដែលជាតឹកតាងបង្ហាញបញ្ជាក់អំពីការពិតនៃខ្លឹមសារដំណាលនេះ។

ដោយទឹកព្រះទ័យប្រោសប្រណី ព្រះករុណាព្រះបាទអង្គឌួងបានព្រះប្រោសប្រទានយសស័ក្តិដល់អ្នកដឹកនាំសាសនាអ៊ិស្លាម(ក្រុមកនអ៊ីម៉ាំសាន់) ចាម្ប៉ានី ដែលគេហៅថា អូងឃ្នរ ជា *ឧកញ៉ាឃ្នរ* ដែលមានស័ក្តិប្រាំពីរហ៊ូពាន់(ស្មើនឹងស័ក្តិមន្រ្តីត្រួតពលចំនួន ៧ពាន់នាក់)។ រហូតមកដល់ឆ្នាំ២០១៧ ក្រុមកនអ៊ីម៉ាំសាន់មានឧកញ៉ាឃ្នរប្រាំបួនរូប(ប្រាំបួនជំនាន់)៖

១- ***ឧកញ៉ាឃ្នរ លឹម*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យឧដុង្គ
២- ***ឧកញ៉ាឃ្នរ ប៉ាន*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យឧដុង្គ
៣- ***ឧកញ៉ាឃ្នរ ហ៊ីម*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យអាណានិគមបារាំង
៤- ***ឧកញ៉ាឃ្នរ ហ្គោមសេស*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យអាណានិគមបារាំង
៥- ***ឧកញ៉ាឃ្នរ កែកក់*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យសង្គមរាស្រ្តនិយម
៦- ***ឧកញ៉ាឃ្នរ ស៊ឹមសាលី*** តែងតាំងដោយព្រះមហាក្សត្រនៅសម័យសង្គមរាស្រ្តនិយម
៧- ***ឧកញ៉ាឃ្នរ លីម៉ាន*** តែងតាំងនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា
៨- ***ឧកញ៉ាឃ្នរ កែទាំ*** តែងតាំងដោយព្រះបាទសម្តចនរោត្តមសីហនុនៃព្រះរាជាណាចក្រកម្ពុជា
៩- ***ឧកញ៉ាឃ្នរ ម៉ាត់សា*** តែងតាំងដោយព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

[1] ប្រភពឯកសារ « សហគមន៍ក្រុមអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់ » ។



*ផ្នូរព្រះអ៊ីម៉ាំសាន់ មេដឹកនាំសាសនាអ៊ិស្លាម និកាយឬក្រុមកនអ៊ីម៉ាំសាន់ដំបូងនៅកម្ពុជា*

*ពិតណាស់ និកាយឬក្រុមកនអ៊ីម៉ាំសាន់គឺស្ថិតនៅក្នុងនិកាយសាហ្វាអ៊ីនៃសាសនាអ៊ិស្លាម។ និកាយសាហ្វាអ៊ីមានប្រវត្តិនៅកម្ពុជាតាំងពីយូរយារណាស់មកហើយ ហើយមានតែមួយ ដោយពុំមានការបែងចែកអ្វីឡើយ។ ពួកគេបានគោរពអ៊ីម៉ាំសាន់ជាគ្រូអាចារ្យនៃសាសនាអ៊ិស្លាម។ ប៉ុន្តែការបែងចែកបានលេចរូបរាងច្បាស់ចាប់ពីអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ខណៈដែលប្រទេសកម្ពុជាកាន់តែបើកទំលាយសម្រាប់ពិភពលោក ហើយមានខ្មែរអ៊ិស្លាមខ្លះបានងាកទៅរកការប្រតិបត្តិសាសនាអ៊ិស្លាមតាមលំអានគម្ពីរកូរ៉ានឱ្យបានជាក់លាក់ តាមរយៈទំនាក់ទំនងនិងទទួលឥទ្ធិពលពីសាសនិកអ៊ិស្លាមនៅប្រទេសម៉ាឡេស៊ីនិងប្រទេសអារ៉ាប់។ ដោយឡែក និកាយឬក្រុមកនអ៊ីម៉ាំសាន់នៅរក្សាការគោរពប្រតិបត្តិសាសានាអ៊ិស្លាមតាមលំនាំដែលធ្លាប់ប្រតិបត្តិកន្លងមក ហើយបានគោរព អ៊ីម៉ាំសាន់ ជាព្រះមួយអង្គរបស់ពួកគេដែរ។*

## ភាសានិងអក្សរចាម

*ជនជាតិចាមមានភាសានិងអក្សរផ្ទាល់របស់ខ្លួន ហើយនៅកំពុងមានអត្ថិភាពរហូតមកដល់សព្វថ្ងៃ។ ជនជាតិចាមនៅកម្ពុជានៅនិយាយភាសាចាមសម្រាប់ទំនាក់ទំនងទូទៅនៅក្នុងសហគមន៍របស់ខ្លួន ដែលធ្វើឱ្យភាសាចាមនៅមានអត្ថិភាពយ៉ាងរស់រវើកនៅឡើយ។ ប៉ុន្តែ អក្សរចាមកំពុងស្ថិតនៅក្នុងស្ថានភាពដែលទាមទារនូវការយកចិត្តទុកដាក់ និងការលើកទឹកចិត្តខ្ពស់ ដើម្បីអភិរក្ស។*

*ក្រុមកនអ៊ីម៉ាំសាន់បានខិតខំព្យាយាមយ៉ាងខ្លាំងក្នុងការអភិរក្សអក្សរចាម ដែលក្នុងនោះមានអក្សរបានី និងអក្សរចាម។ អក្សរបានីប្រើសម្រាប់សូត្រធម៌ថ្វាយបង្គំ និងប្រើនៅពេលធ្វើកិច្ចពិធី ខណៈដែលអក្សរចាមប្រើសម្រាប់សំណេរច្បាប់ប្រុស ច្បាប់ស្រី និងសម្រាប់សំណេរកិច្ចការទូទៅ។ កំណាព្យនិងអត្ថបទរបស់ជនជាតិចាមនាសម័យបុរាណទាំងអស់គឺប្រើប្រាស់អក្សរចាមសម័យបុរាណដើម្បីសរសេរ ហើយឯកសារទាំងនោះនៅមានរក្សាទុករហូតមកដល់សព្វថ្ងៃនេះ។*

អក្សរចាមបុរាណនៅតែត្រូវបានបង្រៀនចំពោះកូនចៅជំនាន់ក្រោយនៃជនជាតិចាមរហូតមក ជាពិសេសនៅតាមសហគមន៍នៃក្រុមកនអ៊ីម៉ាំសាន់។

ដោយក្រុមកនអ៊ីម៉ាំសាន់នៅរក្សាការសូត្រធម៌ថ្វាយបង្គំតាមអក្សរបានី នោះគឺសូរសំឡេងព្យញ្ជនៈនៃពាក្យពេចន៍ធម៌ទាំងនោះមិនដូចគ្នានឹងសំឡេងសូត្រធម៌ថ្វាយបង្គំតាមភាសាអារ៉ាប់នៃគម្ពីរកូរ៉ានឡើយ។ ក្រុមកនអ៊ីម៉ាំសាន់បានធ្វើចាមនីយកម្មលើសំណេរនិងសូរសំឡេងធម៌សម្រាប់សូត្រថ្វាយបង្គំ។



ស្លាកឈ្មោះវិហារក្រុមកនអ៊ីម៉ាំសាន់សរសេរជាអក្សរខ្មែរនិងអក្សរចាម

ខាងក្រោមនេះជាបណ្តាសៀវភៅសរសេរជាភាសាចាម ដែលក្រុមកនអ៊ីម៉ាំសាន់បានចងក្រងឡើងសម្រាប់បង្រៀនកូនចៅរបស់ខ្លួនតជំនាន់ទៅមុខទៀត។ ក្រៅពីគម្ពីរហ្គីត ក្រុមកនអ៊ីម៉ាំសាន់បានធ្វើការចងក្រងនូវសៀវភៅមួយចំនួនទៀត ដូចជា សៀវភៅអក្សរសាស្ត្រចាម សៀវភៅប្រជុំគីតាបនិងតាកាយថាណោ សៀវភៅទំនៀមទម្លាប់ប្រពៃណីចាម និង វចនានុក្រមចាម-ខ្មែរ។

**សៀវភៅអក្សរសាស្ត្រចាម**

សៀវភៅអក្សរសាស្ត្រចាមរៀបចំឡើងដោយក្រុមការងាររបស់លោកឧកញ៉ាឃ្លួរ តាមរយៈគម្រោងអភិរក្សវប្បធម៌ចាមឆ្នាំ២០១០-២០១១ ក្រោមការឧបត្ថម្ភថវិកាដោយស្ថានទូតនៃសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា។ សៀវភៅនេះបានចែកចេញជាបីជំពូក មាន ៥១មេរៀន ដើម្បីបង្រៀនសាសនិកអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់កម្ពុជានៅតាមវិហារ ឱ្យបានដឹងនិងស្គាល់អំពីវប្បធម៌ប្រពៃណី និងទំនៀមទម្លាប់ចាម ជាពិសេសភាសានិងអក្សរសាស្ត្រចាម។ ក្រុមកនអ៊ីម៉ាំសាន់បានចងក្រងសៀវភៅនេះឡើងគឺក្នុងគោលបំណងអភិរក្សអក្សរចាមរបស់ខ្លួន ដោយអាចឱ្យជនជាតិចាមយល់ដឹង ស្វ័យសិក្សា និងជួយថែរក្សាភាសានិងអក្សរសាស្ត្រចាមរបស់ខ្លួន។





សៀវភៅអក្សរសាស្ត្រចាម

**សៀវភៅប្រជុំគីតាបនិងតាកាយថាណោ**

សៀវភៅនេះចងក្រងឡើងដោយក្រុមកនអ៊ីមុាំសាន់ ដើម្បីជាឯកសារសម្រាប់ការប្រតិបត្តិនៅតាមវិហារ-សារ៉ាវ និងការសិក្សាស្រាវជ្រាវផ្សេងៗ។ គោលបំណងមួយទៀតនៃការរៀបចំចងក្រងសៀវភៅនេះ គឺចង់ឱ្យជនជាតិចាមទូទៅមានចំណេះដឹងទូលំទូលាយលើផ្លូវធម៌តាមរបៀបនៃនិកាយក្រុមកនអ៊ីមុាំសាន់កម្ពុជា ជាពិសេសទាក់ទងនឹងការលះបង់និងធ្វើឱ្យខ្លួនល្អផូរផង់។ លើសពីនេះទៀត សៀវភៅនេះបង្ហាញអំពីការអប់រំកាយ វាចា ចិត្ត ឱ្យរួចចាកផុតពីអំពើឃោរឃៅយង់ឃ្នង ដែលបង្កការលំបាកដល់គ្រួសារ សង្គមជាតិ និងពិភពលោកទាំងមូល។




សៀវភៅប្រជុំគីតាបនិងតាកាយថាណោ

**សៀវភៅទំនៀមទម្លាប់ប្រពៃណីចាម**

*សៀវភៅនេះរៀបចំចងក្រងនូវទំនៀមទម្លាប់ ប្រពៃណី ជំនឿ សីលធម៌ សុជីវធម៌ និងរបៀបរស់នៅក្នុងសង្គមប្រកបដោយសុខុដុមរមនារបស់ជនជាតិចាម ដោយមិនប្រកាន់វណ្ណៈ ឋានៈ ពូជសាសន៍ និងជំនឿសាសនា មានជាអាទិ៍ ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យសព ពិធីបុណ្យចូលឆ្នាំចាម(អាសូរ៉ា) ពិធីវន្ទះ និងពិធីសុំទឹកភ្លៀង ជាដើម។ ពិធីទាំងនេះ កំពុងនៅប្រតិបត្តិនៅកម្ពុជានៅឡើយ ហើយជំនឿ ទំនៀមទម្លាប់ និងប្រពៃណីខ្លះ គឺទទួលឥទ្ធិពលពីសង្គមខ្មែរ និងធ្វើសមាហរណកម្មជាមួយសង្គមខ្មែរដែលគេបានរស់នៅ។*




*សៀវភៅទំនៀមទម្លាប់ប្រពៃណីចាម*

**វចនានុក្រមចាម-ខ្មែរ**

*វចនានុក្រមចាម-ខ្មែរមានពាក្យជាភាសាចាមចំនួន៣០០០ពាក្យ មានបង្ហាញសូរអាននិងពន្យល់អត្ថន័យជាភាសាខ្មែរ។ សៀវភៅនេះនឹងជួយសម្រួលដល់អ្នកសិក្សាភាសាចាមឱ្យយល់អំពីសូរអាន អត្ថន័យ និងការប្រើប្រាស់ពាក្យរបស់ប្រជាជនចាមដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការចងក្រងសៀវភៅវចនានុក្រមចាម-ខ្មែរនឹងជួយឱ្យជនជាតិចាមប្រើប្រាស់ភាសាចាមរបស់ខ្លួនបានត្រឹមត្រូវ។*



សៀវភៅវចនានុក្រមចាម-ខ្មែរ

ជារួម ក្រុមកនអ៊ីម៉ាំសាន់បានខិតខំចងក្រងសៀវភៅទាំងអស់នេះឡើងគឺដើម្បីអភិរក្សភាសានិងអក្សរចាម តាមរយៈការចងក្រងទុកជាឯកសារផង និងការជួយសម្រួលដល់អ្នកសិក្សារៀនសូត្រភាសាចាមផង។ ចំពោះមុខ ការអភិរក្សភាសានិងអក្សរចាមគឺទាមទារនូវការយកចិត្តទុកដាក់និងលើកទឹកចិត្តខ្ពស់ពីរាជរដ្ឋាភិបាល។

បច្ចុប្បន្ននេះ មានជនជាតិចាមជាច្រើនមានទំនោរសិក្សាភាសានិងអក្សរម៉ាឡេនិងអារ៉ាប់។ មានទិដ្ឋភាពចំនួនពីរដែលនាំឱ្យខ្មែរអ៊ិស្លាមជំនាន់ក្រោយមានទំនោរសិក្សាភាសាម៉ាឡេ និងភាសាអារ៉ាប់ នោះគឺ ទិដ្ឋភាពសាសនា និងទិដ្ឋភាពសេដ្ឋកិច្ច។ ចំពោះទិដ្ឋភាពសាសនា គឺខ្មែរអ៊ិស្លាមជំនាន់ក្រោយយល់ថា សាសនាអ៊ិស្លាមមានប្រភពកំណើតមកពីប្រទេសអារ៉ាប់ ហើយគម្ពីរគូរ៉ានគឺសរសេរជាភាសាអារ៉ាប់ និងបានបកប្រែជាភាសាម៉ាឡេដែលមានការទទួលស្គាល់។ ចំពោះទិដ្ឋភាពសេដ្ឋកិច្ច គឺការសិក្សាភាសាម៉ាឡេនិងភាសាអារ៉ាប់អាចទទួលបានផលប្រយោជន៍ផ្សេងៗជាច្រើន ដូចជា ការទទួលបានអាហារូបករណ៍ និង ទំនាក់ទំនងជំនួញនិងការងារ ជាដើម។ អាចនិយាយបានថា ភាសានិងអក្សរចាមគឺមានតែទិដ្ឋភាពវប្បធម៌ ដែលមានតម្លៃក្នុងការថែរក្សាភាសាជនជាតិខ្លួន ថែរក្សាកេរដំណែលបុព្វបុរសខ្លួន ប្រើបានតែនៅក្នុងសហគមន៍ខ្លួន តែមិនអាចប្រើនៅប្រទេសដទៃទៀតបាន។

# ជំនឿ ទំនៀមទម្លាប់ ប្រពៃណី

**ពិធីបុណ្យសុំទឹកភ្លៀង**

*ក្រុមកនអ៊ីម៉ាំសាន់មានជំនឿនិងការប្រតិបត្តិពិធីសុំទឹកភ្លៀងដូចខ្មែរដែរ ដោយគ្រាន់តែរបៀបនៃការរៀបចំកិច្ចពិធីនេះមានលក្ខណៈខុសគ្នា។ ប៉ុន្តែ ស្ថានភាពដែលនាំឱ្យមានការរៀបចំពិធីសុំទឹកភ្លៀងនិងគោលបំណងនៃការរៀបចំពិធីនេះ ទាំងខ្មែរ ទាំងខ្មែរអ៊ិស្លាមក្រុមកនអ៊ីមាំសាន់ គឺដូចគ្នា ពោលគឺគេរៀបចំនៅពេលមានសភាពរាំងស្ងួតខ្លាំង គ្មានភ្លៀង គ្មានទឹកសម្រាប់ស្រោចស្រពដំណាំកសិកម្មផ្សេងៗ ហើយដែលត្រូវរៀបចំពិធីសុំទឹកភ្លៀងដើម្បីឱ្យមានភ្លៀងធ្លាក់ មានទឹកស្រោចស្រពដំណាំកសិកម្មរបស់អ្នកភូមិ។*

*ខ្មែររៀបចំកិច្ចពិធីសុំទឹកភ្លៀងដោយមានគ្រឿងសក្ការៈសម្រាប់ពិធី មានម្ហូបអាហាររៀបចំសម្រាប់សែនព្រេន មានការសូត្រធម៌តាមបែបព្រះពុទ្ធសាសនា ឬមានភ្លេង ជាដើម។ ខ្មែរច្រើនធ្វើពិធីសុំទឹកភ្លៀងនៅតាមរោងអ្នកតា។ ដោយឡែក ខ្មែរអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់រៀបចំកិច្ចពិធីសុំទឹកភ្លៀង ដោយចាប់ផ្តើមពីការស្នើឱ្យយាយៗទៅសុំឱ្យខាងតាៗរៀបចំធ្វើពិធីសុំទឹកភ្លៀង។ តាៗជាចាស់ទុំក្នុងភូមិរៀបចំដឹកនាំការសូត្រធម៌នៅកណ្តាលវាលស្រែឬត្រពាំងស្ងួតគ្មានទឹក ក្រោមកម្តៅថ្ងៃក្តៅហែង ដើម្បីសុំពរពីព្រះអល់ឡោះ។ ធម៌ដែលសូត្រក្នុងកិច្ចពិធីនេះ គឺជាធម៌សូត្រថ្វាយបង្គំនៅក្នុងវិហារ។ ជាមួយនេះ អ្នកភូមិត្រូវរៀបចំម្ហូបអាហារជាច្រើនដាក់ក្នុងថាស ដោយមានយាយៗវ័យចំណាស់ធ្វើលាជដាក់ក្នុងថាសផងចូលរួមក្នុងពិធីសូត្រធម៌នោះ។ បន្ទាប់ពីសូត្រធម៌ចប់ គេបាចលាជ ដោយឧបកិច្ចប្រៀបប្រដូចនឹងគ្រាប់ទឹកភ្លៀង ហើយបរិភោគអាហារដែលបានរៀបចំនោះ។ គេត្រូវស៊ូទ្រាំរៀបចំកិច្ចពិធីនេះនៅក្រោមកម្តៅថ្ងៃរហូតដល់ចប់កិច្ចពិធី។*

**អាគមស្តោះផ្លុំ**

*ជនជាតិចាមក្រុមកនអ៊ីម៉ាំសាន់ក៏មានជំនឿទៅលើអាគមស្តោះផ្លុំ និងការលាងអារក្សដូចខ្មែរដែរ។ ក្រុមនេះមានទំនៀមអញ្ជើញគ្រូអាគមមកស្តោះផ្លុំដល់កូនដែលទើបប្រសូត ដើម្បីឱ្យកូននោះមានសេចក្តីសុខសប្បាយ។ គេអាចអញ្ជើញគ្រូអាគមចាមឬគ្រូអាគមខ្មែរឱ្យមកស្តោះផ្លុំដល់កូនរបស់គេ ទៅតាមស្ថានភាពជាក់ស្តែងនិងជំនឿរបស់គេរៀងៗខ្លួន។ គេត្រូវរៀបចំគ្រឿងរណ្តាប់សក្ការៈផ្សេងៗទៅតាមសំណើរបស់គ្រូអាគមម្នាក់ៗ។*

**ពិធីលៀងអារក្ស**

*ជនជាតិចាមក្រុមកនអ៊ីម៉ាំសាន់មានជំនឿ និងការប្រតិបត្តិកិច្ចពិធីលៀងអារក្សដូចខ្មែរដែរ តែការរៀបចំមានលក្ខណៈខុសគ្នា។ ជាទូទៅ រោងអារក្សចាមសង់បែរមុខទៅទិសខាងកើត ដែល*

អាចមានពីរល្វែង បីល្វែង ឬបួនល្វែង ទៅតាមរយៈពេលខ្លីឬវែងនៃការរៀបចំពិធីនោះ។ បើរោងអារក្សរៀបចំសម្រាប់ពិធីរយៈពេលមួយថ្ងៃ គេសង់រោងដោយមានសសរ៤ដើមបែរមុខទៅទិសខាងកើត។ បើរោងអារក្សរៀបចំសម្រាប់ពិធីរយៈពេលមួយថ្ងៃមួយយប់ គេសង់រោងដោយមានសសរ១២ដើម មានបីល្វែង បែរមុខទៅទិសខាងកើត។ បើរោងអារក្សរៀបចំសម្រាប់ពិធីរយៈពេលបីថ្ងៃបីយប់ គេសង់រោងដោយមានសសរសេរសរ១៥ដើម មានបួនល្វែង បែរមុខទៅទិសខាងកើតដែរ។ ចំពោះពិធីលៀងអារក្សរយៈពេលបីថ្ងៃបីយប់ គឺគេមានកាប់ក្របីមួយក្បាលដើម្បីឧទ្ទិសបូជាដល់រូបអារក្ស។ ក្របីនោះត្រូវកាប់ពុះចែកជាពីរ ដោយមួយផ្នែកសម្រាប់តាៗដែលបានមកចូលរួមសូត្រធម៌ និងមួយផ្នែកទៀតសម្រាប់រូបអារក្ស។ រូបអារក្សនៅក្នុងពិធីលៀងអារក្សចាមមានរហូតដល់៤០រូប ហើយរាំពេញរោង។ ភ្លេងអារក្សចាមមានឧបករណ៍ ដូចជា ស្គរកាណាំង សារ៉ាណាយ (ស្រឡៃ) គង និង ក្រាប់ ។

មានការលើកឡើងថា នាសម័យដើម វង់ភ្លេងនេះគឺលេងសម្រាប់តែព្រះមហាក្សត្រចាមនៅក្នុងព្រះបរមរាជវាំង។ ហេតុនេះហើយទើបនៅពេលលេងភ្លេងអារក្ស គឺមានរូបអារក្សចូលជាព្រះមហាក្សត្រ ព្រះស្នំ មេទ័ព សេះ ស្វា និង ដំរី ជាដើម។ ប៉ុន្តែ បន្ទាប់ពីប្រទេសចំប៉ាបាត់បង់ទៅ រូបព្រះមហាក្សត្រ រូបព្រះស្នំ និងរូបមេទ័ពទាំងនោះ ត្រូវគេជឿថាបានមកចូលសណ្ឋិតក្នុងរូបមនុស្ស ហេតុនេះទើបរូបអារក្សចាម មានរហូតដល់៤០រូបរាំក្នុងរោង។

បច្ចុប្បន្ន ជនជាតិចាមក្រុមកនអ៊ីម៉ាំសាន់នៅមានជំនឿនិងនៅបន្តប្រតិបត្តិពិធីលាងអារក្សនៅឡើយ។ « មូលហេតុដែលយើងនៅមានជំនឿ គឺដោយសារពេលចាមខ្វះឈឺ គ្រូពេទ្យព្យាបាលមិនជា ហើយគេធ្វើការបន់ស្រន់ទៅបានសមប្រកប ទើបគេលេងអារក្សថ្វាយ។ យើងមិនអាចហាមឃាត់មិនឱ្យគេប្រតិបត្តិទេ ពីព្រោះវាទាក់ទងនឹងអាយុជីវិតរបស់គេ បើហាមប្រាមគេ ក៏ប្រៀបដូចជាសម្លាប់ជីវិតគេដូច្នេះដែរ» [2] ។

### សម្លៀកបំពាក់

បព្វជិតសាសនាអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់ស្លៀកសំពត់ពណ៌ស ពាក់អាវពណ៌ស ជួតក្បាលនឹងសំពត់ពណ៌ស និងកោសក់។ បព្វជិតសាសនាអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់គឺសំដៅដល់គណៈដឹកនាំនៅតាមវិហារនីមួយៗ មានប្រាំបួនរូបគឺ អ៊ីម៉ាំកូឈួយ អ៊ីម៉ាំស្ដាំ អ៊ីម៉ាំឆ្វេង ខទីបទី១ ខទីបទី២ ពីឡាល់ទី១ ពីឡាល់ទី២ ពីឡាល់ទី៣ និង ពីឡាល់ទី៤។

ចំពោះឧបាសក (ទាំងចាស់ ទាំងក្មេង) ស្លៀកសំពត់និងពាក់អាវពណ៌ចម្រុះ និងមានជួតក្បាលនឹងក្រម៉ា។ ចំពោះឧបាសិកាគឺស្លៀកពាក់តាមវ័យ ដោយស្ត្រីវ័យក្មេងស្លៀកសំពត់ធម្មតា

---

[2] ឧកញ៉ាឃ្លួរ ម៉ាត់ សា ប្រធានសហគមន៍អ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់ (សម្ភាសន៍ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧) ។

ពាក់អាវបំពង់វែងពណ៌ខៀវឬបៃតង និងទទូរស្បៃពណ៌ផ្សេងៗ ឯស្ត្រីវ័យកណ្តាលស្លៀកសំពត់ពណ៌ខ្មៅ ពាក់អាវបំពង់វែងពណ៌ខ្មៅ និងទទូរស្បៃ។ ដោយឡែក ស្ត្រីវ័យចំណាស់ស្លៀកសំពត់ពណ៌ស ពាក់អាវបំពង់វែងពណ៌ស និងទទូរក្រម៉ាដូចគ្នា។[3]

## ការប្រតិបត្តិសាសនា

### វិហារ និង សារ៉ាវ

គេអាចសម្គាល់វិហារ និងសារ៉ាវ នៃក្រុមកនអ៊ីមុាំសាន់ តាមរយៈរចនាបថសំណង់នៃវិហារ និងសារ៉ាវនោះ។ រចនាបថរបស់វិហារនិងសារ៉ាវនៃក្រុមកនអ៊ីមុាំសាន់គឺមានលក្ខណៈសាមញ្ញ មានដំបូលបីថ្នាក់ ដែលបង្កប់នូវអត្ថន័យទាក់ទងនឹង ព្រះអល់ឡោះ មហាម៉ាត់(ជាព្យាការី) និង អាដាម(សាវ័កជាមនុស្ស)[4] ។ វិហារនិងសារ៉ាវនៃក្រុមកនអ៊ីមុាំសាន់មិនមានប៉មនោះទេ។

ខាងក្រោមនេះជាវិហារកែវសរអូរឫស្សី នៅភូមិស្រែប្រិយ ដែលមានប្រជាជនចំណុះវិហារ ប្រមាណជា២៥៤គ្រួសារ ត្រូវជា៨៨៩នាក់ ដោយភាគច្រើនជាមនុស្សស្ថិតក្នុងវ័យកណ្តាល។



វិហារកែវសរអូរឫស្សីភូមិស្រែប្រិយ និង ទិដ្ឋភាពខាងក្នុងនៃវិហារ

### ការថ្វាយបង្គំព្រះ

សាសនិកអ៊ិស្លាមក្រុមកនអ៊ីមុាំសាន់ប្រតិបត្តិការថ្វាយបង្គំព្រះតែម្តងប៉ុណ្ណោះនៅក្នុងមួយសប្តាហ៍គឺនៅថ្ងៃសុក្រ។ ការប្រតិបបត្តិនេះមានលក្ខណៈដោយឡែកផ្ទាល់របស់ខ្លួន ខណៈដែលសាសនិកអ៊ិស្លាមនៃនិកាយដទៃទៀតនៅកម្ពុជា ជាទូទៅប្រតិបត្តិការថ្វាយបង្គំ៥ដងក្នុង១ថ្ងៃ។

---

[3] ឯកសារសហគមន៍ក្រុមកនអ៊ីមុាំសាន់។

[4] ឧកញ៉ាឃ្លួរ ម៉ាត់ សា ជំនាន់ទី៩ (មេដឹកនាំសហគមន៍អ៊ិស្លាមក្រុមកនអ៊ីមុាំសាន់)។

ក្រុមកនអ៊ីម៉ាំសាន់សូត្រធម៌ថ្វាយបង្គំដោយផ្អែកលើគម្ពីរ ហ្គីត។ គម្ពីរ ហ្គីតជាការសំយោគដកស្រង់នូវខ្លឹមសារសំខាន់ ខ្លឹមសារគោលចេញពីគម្ពីរ គូរ៉ាន់ ដែលជាគម្ពីរគោលដើមរបស់សាសនាអ៊ិស្លាម។ គម្ពីរហ្គីតមានតាំងពីជំនាន់ឧកញ៉ាឃ្លួរជំនាន់ដំបូងមកម៉្លេះ គ្រាន់តែពីដំបូងគេសរសេរលើក្រដាស់ស៊ីម៉ង់ពណ៌ជីឥដ្ឋ ហើយក្រោយមក មានការចម្លងនិងចងក្រងជាគម្ពីរ ហ្គីតនេះឡើង។



គម្ពីរ ហ្គីត សម្រាប់សាសនិកអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់ប្រតិបត្តិ

**ពិធីបុណ្យសាសនាអ៊ិស្លាមនៅកម្ពុជា**

ក្រុមកនអ៊ីម៉ាំសាន់ប្រតិបត្តិពិធីបុណ្យធំៗនៅក្នុងសាសនាអ៊ិស្លាមគឺ បុណ្យម៉ៅឡូត់(បុណ្យកំណើតព្រះ) បុណ្យរ៉ាម៉ាឌន(បុណ្យបួសតមចំណីអាហារ) និង បុណ្យហាជី(បុណ្យកាប់គោ)។ ក្រៅពីពិធីបុណ្យធំៗទាំងបីនេះ ក្រុមកនអ៊ីម៉ាំសាន់មានប្រារព្ធពិធីបុណ្យអាស្ហូរ៉ា(បុណ្យចូលឆ្នាំចាម)ផងដែរ ដោយក្រុមនេះនៅរក្សានិងបានផ្សារភ្ជាប់ខ្លួននឹងអតីតកាលជាជនជាតិចាមនៃនគរចំប៉ាដែលបានបាត់បង់ទៅ។

## បុណ្យអាស្ហូរ៉ា(បុណ្យចូលឆ្នាំចាម)

ក្រុមកនអ៊ីម៉ាំសាន់តែងប្រារព្ធពិធីបុណ្យអាស្ហូរ៉ាជាទៀងទាត់ ដោយប្រារព្ធនៅថ្ងៃទី ១១ កើត ខែទីមួយ (អាល់មូហារ៉ម) នៃមហាម៉ាត់សករាជ។ ជាទូទៅ ពិធីបុណ្យអាស្ហូរ៉ាត្រូវប្រារព្ធរយៈពេលមួយព្រឹក ហើយនៅវេលាម៉ោង១២ថ្ងៃត្រង់ បរិស័ទអ៊ិស្លាមស្លៀកសម្លៀកបំពាក់ពណ៌ស ចូលវិហារ ដើម្បីសូត្រធម៌ថ្វាយបង្គំព្រះសុំសេចក្តីសុខសប្បាយ ចម្រុងចម្រើន។ នៅក្នុងពិធីនេះដែរ ក្រៅ

*ពីការធ្វើអាហារសម្រាប់ទទួលទានធម្មតា ដូចជាសម្លការីឬជាសម្លផ្សេងៗទៀតនោះ គឺគេត្រូវធ្វើបបរខ្មៅដែលជាអាហារពិសេសសម្រាប់ពិធីបុណ្យនេះ។*

*បបរខ្មៅធ្វើឡើងដោយផ្សំពីគ្រាប់ធញ្ញជាតិប្រាំពីរប្រភេទ ដូចជា អង្ករដំណើប លូខ្មៅ គ្រាប់សណ្ដែកដី គ្រាប់ល្ពៅ គ្រាប់ពោត គ្រាប់ននោង និង គ្រាប់សណ្ដែកបាយ ជាដើម។ គេយកគ្រាប់ធញ្ញជាតិទាំងនោះបុកលាយជាមួយអង្ករដំណើប ហើយបបរឱ្យទៅជាខាប់។ បន្ទាប់មក គេចៀនពងមាន់ឬពងទាឱ្យសំប៉ែត ហើយហាន់ជាចំណិតសរសៃស្ដើងៗទុកសម្រាប់ដាក់ពីលើបបរនោះ។ ជាធម្មតា គេរៀបចំបបរខ្មៅចំនួនបីចានដាក់លើថាស់ ដោយក្នុងចាននីមួយៗមានដាក់ចំណិតពងមាន់ឬពងទាដែលគេហាន់ជាសរសៃស្ដើងៗ រៀបដាក់ខ្វែងគ្នាជាពីរជាន់ ដោយជាន់ខាងក្រោមដាក់ពងមាន់ឬពងទាប្រាំពីរជួរ និងជាន់ខាងលើដាក់ពងមាន់ឬពងទាចំនួនប្រាំបួនជួរ។ ជាន់ខាងលើនិងជាន់ខាងក្រោមត្រូវដាក់ខ្វែងគ្នាដូចជាសញ្ញាលេខបូក។*

*ក្រៅពីបបរខ្មៅ នៅក្នុងថាសនោះក៏មានដាក់សម្លផ្សេងទៀតដែរ។ បន្ទាប់មក ពួកគេនាំគ្នាបរិភោគអាហារដោយរួមទាំងបបរខ្មៅនោះ។ មានការលើកឡើងថា អត្ថន័យនៃពិធីបុណ្យនេះក៏ចង់បង្ហាញពីបន្សំនៃធាតុផ្សេងៗដែលនាំឱ្យមានការចាប់កំណើតផងដែរ។ ដោយហេតុនេះហើយទើបពួកគេធ្វើបបរខ្មៅដែលផ្សំពីគ្រាប់ធញ្ញជាតិជាច្រើនមុខនេះឡើង។*

### *បុណ្យម៉ៅឡូត់*

*បុណ្យម៉ៅឡូត់ជាពិធីបុណ្យខួបកំណើតព្រះ ដែលត្រូវប្រារព្ធជាទូទៅសម្រាប់គ្រប់និកាយនៃសាសនាអ៊ិស្លាម។ នៅកម្ពុជា គេប្រារព្ធពិធីបុណ្យនេះម្ដងក្នុងមួយឆ្នាំ គឺនៅក្នុងខែកុម្ភៈឬមីនា (អាស្រ័យលើការគន់គូរពិភាក្សារបស់អ្នកដឹកនាំសាសនាក្នុងសហគមន៍) ហើយមានរយៈពេលមួយថ្ងៃពេញ[5]។*

*នៅកម្ពុជា សាសនិកអ៊ិស្លាមប្រារព្ធពិធីបុណ្យម៉ៅឡូត់ក្នុងគោលបំណង៖ ទី១ រំលឹកដល់ថ្ងៃកំណើតរបស់ព្រះមហាម៉ាត់, ទី២ ដើម្បីសុំសេចក្ដីសុខ សេចក្ដីចម្រុងចម្រើនដល់របរចិញ្ចឹមជីវិតនិងការរស់នៅរបស់ជនជាតិចាមនៅក្នុងសហគមន៍, ទី៣ រំលឹកដល់ការកកើតជីវិតមនុស្ស និងទី៤ ដើម្បីរឹតចំណងសាមគ្គីភាពនៅក្នុងសហគមន៍។ នៅថ្ងៃបុណ្យនេះ មានប្រជាជនជាច្រើនមកជួបជុំគ្នានៅតាមវិហារ ទាំងប្រជាជនក្នុងភូមិ ទាំងប្រជាជនមកពីក្រៅភូមិ ហើយពួកគេរៀបចំទទួលទានអាហារនិងនំចំណីជាមួយគ្នា។ ក្នុងពិធីបុណ្យនេះ គេក៏អាចប្រមូលបច្ច័យសម្រាប់បម្រើផលប្រយោជន៍របស់សហគមន៍ដែរ ដូចជាសម្រាប់ការកសាងវិហារ សាលារៀន និងបម្រើការសាសនាផ្សេងៗ។*

---

[5] *ម៉ាន ម៉ាត់ ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ាកម្ពុជា។*

*សម្រាប់សាសនិកអ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់ គឺមានទម្លាប់រៀបចំធ្វើពិធីបុណ្យម៉ៅឡូត់នៅវិហារកែវសរអូរឫស្សី នៅភូមិស្រែប្រិយ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងជាមុន រួចទើបរៀបចំនៅតាមវិហារចំណុះនៃនិកាយកនអ៊ីម៉ាំសាន់ជាបន្តបន្ទាប់គ្នា។ សម្រាប់ពិធីបុណ្យម៉ៅឡូត់ សាសនិកអ៊ិស្លាម ជាពិសេសក្រុមកនអ៊ីម៉ាំសាន់នៅខេត្តកំពង់ឆ្នាំង មានទំនៀមធ្វើនំជាច្រើនប្រភេទ មានដូចជា នំផ្កា នំសម្បុកចាប នំអន្សម នំគម នំកន្ត្រាំ និង នំចាក់ចុល ជាដើម។*

*ជនជាតិចាមក្រុមកនអ៊ីម៉ាំសាន់មានទំនៀមធ្វើនំផ្កាតាំងពីបុរាណមក ហើយរហូតមកដល់បច្ចុប្បន្ននេះ ស្ត្រីជនជាតិចាមមានវ័យចំណាស់សុទ្ធសឹងចេះធ្វើនំនេះស្ទើរគ្រប់គ្នា ជាពិសេសជនជាតិចាមរស់នៅខេត្តកំពង់ឆ្នាំង។ « ដោយសារបុណ្យនេះមាននិយាយអំពីកំណើត ហេតុនេះហើយទើបគេធ្វើនំតំណាងកំណើតមនុស្សទាំងក្នុងខ្លួនមនុស្សនិងក្រៅខ្លួនមនុស្ស»[6] ។*

*នំផ្កាមានទម្រង់ផ្សេងៗគ្នាជាច្រើន[7] ហើយនំនីមួយៗក៏មានបង្កប់នូវអត្ថន័យរបស់វាដែរ។ ក្នុងចំណោមនោះ មាននំផ្កាប្រភេទខ្លះមានរាងដូចក្បាច់ចម្លាក់នៅតាមប្រាសាទ ខ្លះមានរាងជាផ្កា ខ្លះមានរាងដូចប្រាសាទ(តំណាងមនុស្សស្រី) ខ្លះមានរាងមយូរា(តំណាងមនុស្សប្រុស) ខ្លះមានរាងកងចក្រ(សំដៅភពផែនដី) នំមានមុំបួន(សំដៅធាតុ ទឹក ដី ភ្លើង ខ្យល់) នំមានមុំប្រាំ(សំដៅលើបញ្ចក្ខន្ធទាំងប្រាំរបស់មនុស្ស) និង នំមានមុំប្រាំមួយ(សំដៅអាកប្បកិរិយាទាំងប្រាំមួយរបស់មនុស្ស គឺ ស្អប់ ស្រឡាញ់ ខឹង ប្រចណ្ឌ ច្រណែន និងចង់មានបាន) នំមានមុំប្រាំពីរ(សំដៅលើសរីរាង្គរបស់មនុស្ស)។ យើងមិនធ្លាប់បានឃើញខ្មែរមានធ្វើនំផ្កានេះសម្រាប់ពិធីបុណ្យខ្មែរនោះទេ។*



*នំផ្កា(រាងកងចក្រ)*



*នំផ្កា(មុំប្រាំមួយ)*

[6] *ឧកញ៉ាឃ្នួរ ម៉ាត់ សា ប្រធានសហគមន៍អ៊ិស្លាមក្រុមកនអ៊ីម៉ាំសាន់។ (សម្ភាសន៍ថ្ងៃទី១០ ខែកុម្ភៈឆ្នាំ២០១៧)*

[7] *រូបភាពនំផ្កាទាំងនេះ គ្រាន់តែជាទម្រង់មួយចំនួនដែលយើងទទួលបានពីក្រុមកនអ៊ីម៉ាំសាន់ប៉ុណ្ណោះ។ តាមពិតមាននំផ្កាជាច្រើនទម្រង់ទៀត តែសោកស្តាយដែលយើងមិនបានទៅក្នុងអំឡុងពេលគេធ្វើនំសម្រាប់ប្រារព្ធពិធីបុណ្យ។*



នំផ្កា(រាងប្រាសាទ)



នំផ្ការាងមយូរា(តំណាងមនុស្សប្រុស)

### បុណ្យរ៉ាម៉ាឌន (បុណ្យបួសតមចំណីអាហារ)

បុណ្យរ៉ាម៉ាឌន (បុណ្យបួសតមចំណីអាហារ) ត្រូវបានរៀបចំឡើងនៅខែទី៩ នៃមហាម៉ាត់សករាជ។ ការតមចំណីអាហារជាកាតព្វកិច្ចទី៤ នៅក្នុងចំណោមកាតព្វកិច្ចជាមូលដ្ឋានចំនួន៥ របស់សាសនិកអ៊ិស្លាមនៅទូទាំងពិភពលោក។ សាសនិកអ៊ិស្លាមគ្រប់រូបត្រូវបួសតមចំណីអាហារ

រយៈពេលមួយខែក្នុងមួយឆ្នាំ។ សាសនិកអ៊ិស្លាមដែលអាចរួចផុតពីកាតព្វកិច្ចនេះមាន ក្មេងមិនទាន់ពេញវ័យ (ក្រោមអាយុ១៥ឆ្នាំ) និង អ្នកជំងឺ ។ ចំពោះអ្នកជំងឺក៏អាចបំពេញកាតព្វកិច្ចនេះ (ដោយការស្ម័គ្រចិត្ត)បន្ទាប់ពីគេបានជាសះស្បើយពីជំងឺរបស់គេដែរ។

ក្នុងរយៈពេល៣០ថ្ងៃឬ១ខែនោះ សាសនិកអ៊ិស្លាមត្រូវតមចំណីអាហារនៅវេលាពេលថ្ងៃជារៀងរាល់ថ្ងៃ ដោយគិតចាប់ពីពេលថ្ងៃរះចេញពន្លឺរហូតដល់ពេលយប់ងងឹត។ ការតមចំណីអាហារនេះគឺមិនត្រូវបរិភោគអ្វីសោះ សូម្បីតែទឹកមាត់ក៏មិនត្រូវលេបដែរ។ ជាមួយនេះ សាសនិកអ៊ិស្លាមត្រូវជៀសវាងការប្រើសម្តីមិនសមរម្យ ភូតភរកុហកបោកប្រាស់ ឬ ជេរប្រមាថ ជាដើម[8] ។

គោលបំណងនៃការរៀបចំពិធីបុណ្យនេះ គឺដើម្បីបង្ហាញអំពីភាពស្មោះស្ម័គ្ររបស់សាសនិកអ៊ិស្លាមចំពោះព្រះអល់ឡោះ និង ដើម្បីដាស់តឿនដល់មនុស្សគ្រប់រូបឱ្យស្គាល់អំពីការលំបាករបស់អ្នកក្រ ហើយរស់នៅផ្សារភ្ជាប់ជីវិតជាមួយអ្នកក្រដោយការធ្វើទានឬបរិច្ចាកដល់អ្នកក្រីក្រ។

ដោយឡែក ចំពោះក្រុមកនអ៊ីមុាំសាន់ បន្ទាប់ពីស្រាយបួសរួច គេអាចទៅផ្នូរបុព្វការីជនរបស់ខ្លួនដើម្បីធ្វើពិធីបង្សុកូល។ របៀបរបបបង្សុកូលរបស់ជនជាតិចាម គឺគេសម្អាតផ្នូរ ចាក់ដីពូនផ្នូរ ស្រោចទឹកផ្នូរ និងមានចាស់ទុំសូត្រធម៌ (មិនមានការសែនព្រេនម្ហូបអាហារដូចជនជាតិខ្មែរឬចិនទេ)។

## បុណ្យហាជី (បុណ្យកាប់គោ)

សាសនិកអ៊ិសស្លាមគ្រប់រូប ជាពិសេសអ្នកមានជីវភាពធូរធារនិងមានសុខភាពល្អ មានកាតព្វកិច្ចត្រូវទៅធ្វើហាជីនៅទីក្រុងម៉ាកាស ប្រទេសអារ៉ាប់ប៊ីសាអូឌីត ដែលជាទឹកដីកំណើតព្រះយ៉ាំងហោចណាស់ឱ្យបានម្តងក្នុងមួយជីវិតរបស់ខ្លួន។ ចំពោះសាសនិកអ៊ិស្លាមដែលមានលទ្ធភាពនិងសុខភាពល្អ តែមិនបានបំពេញកាតព្វកិច្ចនេះ នោះគេនឹងទទួលបាប ដោយមិនគោរពច្បាប់សាសនា។ នេះជាកាតព្វកិច្ចទី៥ សម្រាប់សាសនិកអ៊ិស្លាម។

នៅសម័យមុន កម្រមានខ្មែរអ៊ិស្លាមបានបំពេញកាតព្វកិច្ចនេះណាស់ ដោយសារកត្តាជីវភាពនិងមធ្យោបាយធ្វើដំណើរ។ ការធ្វើដំណើរគឺត្រូវធ្វើដំណើរតាមកប៉ាល់ទឹក(មិនទាន់មានយន្តហោះ)ដែលត្រូវចំណាយពេលវេលាយ៉ាងតិច ៤ខែ និងត្រូវចំណាយថវិកាច្រើន។ ហេតុនេះខ្មែរអ៊ិស្លាមដែលបានទៅបំពេញកាតព្វកិច្ចនៅសម័យនោះ គឺទទួលបាននូវការផ្តល់តម្លៃនិងការគោរពយ៉ាងខ្ពស់។ បច្ចុប្បន្ន មានខ្មែរអ៊ិស្លាមជាច្រើនបានទៅបំពេញកាតព្វកិច្ចនេះ តាមរយៈការចំណាយថវិកាផ្ទាល់ខ្លួន ទាំងតាមរយៈការទទួលជំនួយសប្បុរសជម៌ពីក្រៅប្រទេស។

---

[8] ឧកញ៉ាឃ្លូរ ម៉ាត់ សា ប្រធានសហគមន៍អ៊ិស្លាមក្រុមកនអ៊ីមុាំសាន់។ (សម្ភាសន៍ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧) ។

*ដោយឡែក សាសនិកអ៊ិស្លាមកម្ពុជាដែលពុំបានទៅចូលរួមបុណ្យហាជីនៅទីក្រុងម៉ាកាស គឺរៀបចំពិធីបុណ្យមួយហៅថា បុណ្យកាប់គោ ដោយអ្នកមានលទ្ធភាពត្រូវបរិច្ចាគប្រាក់ទិញគោ (អាចជាសត្វពពែ ចៀម ឬ ក្របី ជាដើម) មកកាប់យកសាច់ចែកទានដល់សាសនិកអ៊ិស្លាមក្រីក្រ តាមរយៈគណៈកម្មការមួយ។ បុណ្យនេះអាចប្រព្រឹត្តទៅរយៈពេលបួនថ្ងៃ ប្រសិនបើមានគោច្រើនសម្រាប់កាប់ធ្វើទាន។ បន្ថែមលើសាច់គោ គេក៏អាចចែកទានជាអង្ករឬវត្ថុទានផ្សេងៗទៅតាមលទ្ធភាពដែរ។*

## សេចក្តីសន្និដ្ឋាន

*ក្រុមកនអ៊ីម៉ុាំសាន់នៃនិកាយសាសនាអ៊ិស្លាមគឺមានតែនៅកម្ពុជាប៉ុណ្ណោះ ដោយមានប្រវត្តិកកើតឡើងនៅកម្ពុជាក្នុងសម័យឧត្តុង្គ។ ចំនួនសាសនិកអ៊ិស្លាមក្រុមកនអ៊ីម៉ុាំសាន់មានការធ្លាក់ចុះជាបន្តបន្ទាប់ ដោយមានសាសនិកខ្លះមានទំនោរប្រតិបត្តិសាសនាអ៊ិស្លាមតាមគម្ពីរកូរ៉ានដែលជាគម្ពីរដើមនៃសាសនាអ៊ិស្លាមយ៉ាងម៉ឺងម៉ាត់ ដែលទទួលឥទ្ធិពលពីទំនាក់ទំនងនិងជំនួយផ្សេងៗពីសាសនិកអ៊ិស្លាមនៅប្រទេសអារ៉ាប់និងម៉ាឡេស៊ី។ បច្ចុប្បន្ន សាសនិកអ៊ិស្លាមក្រុមកនអ៊ីម៉ុាំសាន់មានប្រមាណ ៣%[9] នៃសាសនិកអ៊ិស្លាមនៅកម្ពុជា។*

*ក្រុមកនអ៊ីម៉ុាំសាន់ជាក្រុមសាសនិកអ៊ិស្លាមនៅកម្ពុជាដែលព្យាយាម និងយកចិត្តទុកដាក់ខ្ពស់ក្នុងការរក្សាអត្តសញ្ញាណរបស់ខ្លួនជាជនជាតិចាម តាមរយៈការខិតខំអភិរក្សភាសាចាម អក្សរចាម និងទំនៀមទម្លាប់ប្រពៃណីចាម។ ជំនួយទាំងឡាយដែលនាំឱ្យប៉ះពាល់ដល់អត្តសញ្ញាណរបស់ខ្លួនឬជាជំនួយមានលក្ខខណ្ឌ គឺក្រុមនេះមិនទទួលឡើយ។*

*ក្រុមកនអ៊ីម៉ុាំសាន់មានលក្ខណៈធ្វើសមាហរណកម្ម និងសំយោគច្រើនជាមួយនឹងវប្បធម៌ប្រពៃណីនិងសង្គមខ្មែរ។ ជំនឿនិងទំនៀមទម្លាប់មួយចំនួនគឺទទួលឥទ្ធិពលពីជំនឿនិងទំនៀមទម្លាប់ខ្មែរ។ លក្ខណៈនេះបង្ហាញអំពីការរស់នៅដោយផ្សារភ្ជាប់នឹងសង្គមខ្មែរ ចុះសម្រុងជាមួយសង្គមខ្មែរ។*

[9] *ប្រភពឯកសារ «សហគមន៍អ៊ិស្លាមក្រុមកនអ៊ីម៉ុាំសាន់»។*

## ឯកសារពិគ្រោះ

ឯកសារ

-មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ « *ក្រុមជនជាតិភាគតិចនៅកម្ពុជា* » បោះពុម្ពលើកទី២ ឆ្នាំ២០១៥។

- ហ្សង់មីសែលហ្វីលីពី *ការស្រាវជ្រាវបឋមអំពីភាសាជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពឆ្នាំ២០០៩។

- *ប្រភពឯកសារ «សហគមន៍ក្រុមអុិស្លាមក្រុមកនអុីម៉ាំសាន់»* ។

សម្ភាសន៍

- *ជុំ សំអាង មន្ត្រីការិយាល័យនៃមន្ទីរធម្មការនិងសាសនាខេត្តកំពង់ឆ្នាំង។ (សម្ភាសថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)*

- *ទេ ម៉ាត់លី អុីម៉ាំឬអ្នកដឹកនាំវិហារអុិស្លាមមួយនៅក្នុងខេត្តកំពង់ឆ្នាំង។ (សម្ភាសថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)*

- *ម៉ាន ម៉ាត់ ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ានៅកម្ពុជា (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)។*

- *លីហ្សាកុបហាគឹមវិហារ (សង្រ្គាជវិហារ) អាល់ម៉ាក់មូរនៅភូមិច្រករមៀត ឃុំឈូកសស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង។ (សម្ភាសថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)*

- *សរ លាង ប្រធានមន្ទីរធម្មការនិងសាសនាខេត្តកំពង់ឆ្នាំង។ (សម្ភាសថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)*

- *ម៉ាត់ សា ឧកញ៉ាឃ្នរជំនាន់ទី៩ និងគណៈដឹកនាំនៃសហគមន៍អុិស្លាមក្រុមកនអុីម៉ាំសាន់ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)។*



ជំនួបរវាងក្រុមស្រាវជ្រាវជាមួយប្រធានមន្ទីរធម្មការនិងសាសនាខេត្តកំពង់ឆ្នាំង



ក្រុមស្រាវជ្រាវជួបសម្ភាសឧកញ៉ាឃ្នួរ ម៉ាត់ សា និងគណៈដឹកនាំក្រុមកនអ៊ីម៉ាំសាន់



លោកស្រី ម៉ិល វាសនា ធ្វើសម្ភាសឧកញ៉ាឃ្នួរ ម៉ាត់ សា